ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០១៦

រៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

# ១. សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ) ជាស្ថាប័នជាតិតែមួយគត់ដែលមានតួនាទីដឹកនាំគ្រប់គ្រង សម្របសម្រួល និងតាមដានការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការឆ្លើយតបទូលំទូលាយ និងពហុវិស័យ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំ និងសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការផលិត និងអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបទូលំទូលាយ និងពហុវិស័យមួយ យោ ងតាមការអនុវត្តគោលការណ៍បី-មួយ និងក្នុងគោលបំណងធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅជាយុទ្ធសាស្ត្របី-សូន្យ ឆ្នាំ២០២០ (មិនមានការ ឆ្លងមេរោគអេដស៍ថ្មី មិនមានការស្លាប់ដោយសារជំងឺអេដស៍ មិនមានការរើសអើង និងមាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍) ព្រមទាំងគោលដៅ ៩០/៩០/៩០ នៃអង្គការ ( UNAIDS) គឺ ៩០%នៃអ្នកផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាម៩០% នៃអ្នកមានតេស្តឈាមវិជ្ជមានបានទទួលការព្យាបាល និង ៩០% នៃអ្នកបានទទួលការព្យាបាលមានវិរុសឲ្យនៅក្រោមកម្រិតមើលឃើញ។ ដើម្បីតាមដានការអនុវត្តភារកិច្ចនេះ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ជាសេនាធិការ មានតួនាទីរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជាពហុវិស័យស្តីអំពីសកម្មភាព វឌ្ឍនភាព និងសមិទ្ធផលដែលទទួលបានពីការអនុវត្តសកម្មភាពការងាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងអគ្គលេខាធិការដ្ឋាន ព្រមទាំងមន្ត្រីនៃនាយកដ្ឋានទាំងអស់ និងស្ថាប័នពាក់ព័ន្ធ។

របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០១៦នេះរួមបញ្ចូលនូវវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីដូចខាងក្រោម៖

- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន។

- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។
- ទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋាននីមួយៗ ។

# ២. សកម្មភាព និងសមិទ្ធផល

## ២.១. សកម្មភាព និងសមិទ្ធផលដែលសម្រេចបានដោយថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅខែឧសភានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយនឹងថ្នាក់ដឹកនាំទាំងអស់បានដឹកនាំធ្វើសកម្មភាពការងារ និងសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំកំពូលពិភាក្សារបាយការណ៍គោលនយោបាយសកលផ្ញើជូនអង្គការសហប្រជាជាតិ៖

នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារ កាំបូឌីយ៉ាណា **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីត្រៀមលក្ខណៈចូលរួមនៅក្នុងកិច្ចប្រជុំកំពូលនៅអង្គសហប្រជាជាតិនាថ្ងៃទី ០៨ ដល់ ទី១០ ខែមិថុនា ឆ្នាំ២០១៦ ។ កិច្ចប្រជុំពិគ្រោះយោបល់នេះត្រូវបានផ្តួចផ្តើម និងរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយសហការជាមួយអង្គការសហប្រជាជាតិ (UNAIDS) **ស្តីពីការងារអេដស៍**។ កិច្ចប្រជុំពិគ្រោះយោបល់នេះ មានបំណងប្រមូលមតិយោបល់ ធ្វើបច្ចុប្បន្នភាព ស្វែងយល់ និងកំណត់បញ្ហានានាពាក់ព័ន្ធទៅនឹងការប្រយុទ្ធជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឈានទៅកំណត់គោលនយោបាយ បញ្ចប់ការចម្លងមេរោគអេដស៍ឲ្យបានត្រឹមឆ្នាំ២០២៥ សំរាប់ព្រះរាជាណាចក្រកម្ពុជា និងដើម្បីចូលរួមចំណែកក្នុងកិច្ចប្រជុំកំពូល អង្គការសហប្រជាជាតិ ក្នុងការកំណត់ទិសដៅគោលនយោបាយសាកលបញ្ចប់ការចម្លងមេរោគអេដស៍ត្រឹមឆ្នាំ២០៣០។ អញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នោះ មានតំណាងក្រសួង ស្ថាប័ន អង្គការសហប្រជាជាតិ តំណាងសង្គមស៊ីវិល ក្រុម ជនដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ និងដៃគូពាក់ព័ន្ធជាច្រើនផ្សេងទៀត។

**- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី**បានអញ្ជើញជាអធិបតី បើកកិច្ចប្រជុំ វាយតំលៃសកម្មភាពការងារ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងមូលនិធិសកលៈ

នៅព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលគម្រោងមូលនិធិសកលបានអញ្ជើញជាអធិបតីបើកកិច្ចប្រជុំវាយតំលៃសកម្មភាពការងាររបស់គណៈកម្មាធិការ និងតំរង់ទិសសកម្មភាពការងារសម្រាប់សមាជិក សមាជិកា ដែលទើបត្រូវបានជ្រើសតាំងថ្មី។ គួររំលឹកថាគណៈកម្មាធិការសម្របសម្រួលគម្រោងមូលនិធិសកល គឺជាគណៈកម្មាធិការ ដែលមានសមាជិកជាតំណាងក្រសួង ស្ថាប័នមួយចំនួនរបស់រាជរដ្ឋាភិបាល តំណាងអង្គការសហប្រជាជាតិ តំណាងស្ថានទូតជាម្ចាស់ជំនួយដែលផ្តល់មូលនិធិ តំណាងអង្គការសង្គមស៊ីវិល និងតំណាងប្រជាពលរដ្ឋដែលរស់នៅជាមួយមេរោគអេដស៍ និងអ្នករងផលប៉ះពាល់ដោយសារជំងឺអេដស៍ របេង និងគ្រុនចាញ់នៅព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មាធិការសម្របសម្រួលគម្រោងមូលនិធិសកលមានភារកិច្ចទទួលខុសត្រូវសម្របសម្រួលផែនការ និងសំណើគម្រោងកម្មវិធី អនុវត្តគម្រោងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ឲ្យបានស្របទៅនឹងលក្ខខណ្ឌជំនួយមូលនិធិសកល និងស្ថានភាពប្រយុទ្ធ និងឆ្លើយតបទៅនឹងជំងឺទាំងបី។ រហូតមកដល់បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់ឱសថប្រឆាំងមេរោគ អេដស៍ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ប្រមាណ៥៧០០០នាក់ បានផ្តល់ការព្យាបាលដល់អ្នកជំងឺរបេងប្រមាណ១៣ម៉ឺននាក់ និងបែងចែកមុងជ្រលក់ថ្នាំកំចាត់មូសការពារជំងឺគ្រុនចាញ់បានចំនួនប្រាំលានប្រាំមួយសែនមុង ដែលជាជំនួយរបស់មូលនិធិសកល ។

**- ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី**បានចូលរួមក្នុងកម្មវិធីវេទិកាសាធារណៈ នៅក្នុងវត្តសេរីសោភណ្ឌ ឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

នាព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី**ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកបសេដ្ឋ បានចូលរួមក្នុងកម្មវិធីវេទិកាសាធារណៈ នៅក្នុងវត្តសេរីសោភណ្ឌ នៃឃុំកាត់ភ្លុក ដោយមានការចូលរួមពីប្រជាពលរដ្ឋមកពី ភូមិព្រៃសំព័រ ភូមិថ្លុកក្របី ភូមិវាលរវាង និងភូមិត្រពាំងពើក ឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ចំនួនជិតបួនរយនាក់។ ចូលរួមអមដំណើរមានលោកជំទាវ ហោ ម៉ាលីន រដ្ឋលេខាធិការក្រសួងកសិកម្ម ឯកឧត្តម ណី ណន់ អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឯកឧត្តម

អស់លោកថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងអស់លោកលោកស្រីប្រធាន និងអ្នកទទួលខុសត្រូវតាមមន្ទីរប្រចាំខេត្ត អភិបាល អភិបាលរងស្រុក លោកមេឃុំ សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ។ ប្រជាពលរដ្ឋផ្តោតការយកចិត្តដាក់លើបញ្ហាសុវត្ថភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម បញ្ហាសំបុត្រអត្រានុកូលដ្ឋាន និងបញ្ហាខ្វះទឹកធ្វើស្រែចំការ ដោយមិនមានភ្លៀង។ ក្រុមការងារថ្នាក់ជាតិ និងមន្ត្រីទទួលខុសត្រូវប្រចាំស្រុកបានធ្វើការពន្យល់ និងរកវិធីដោះស្រាយលើបញ្ហាទាំងអស់នេះ ដែលប្រជាពលរដ្ឋអាចទទួលយកបាន។

<u>**កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**</u>

នៅព្រឹកថ្ងៃ ទី២៧ ខែឧសភា ឆ្នាំ២០១៦ នៅទីស្តីការ វិមានសន្តិភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការ វិមានសន្តិភាព រាជធានីភ្នំពេញ។

<u>**របៀបវារៈនៃកិច្ចប្រជុំមាន៖**</u>

១. សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។
២. បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញាតិលើ៖
   - ពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។
   - កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន រួមទាំងពិធីសារចំនួន០២។
   - ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានអញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនោះ ផងដែរ។ បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់យ៉ាងយូរគណៈរដ្ឋមន្ត្រី បានពិនិត្យអនុម័តលើ សេចក្តីព្រាងច្បាប់ ខាងលើ។ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ០៩ និង ៤៥នាទី។

កិច្ចប្រជុំស្តីពីការពិនិត្យលទ្ធផលនៃការអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

វេលាម៉ោង ០៩:០០ នាទីព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នៅទីស្តីការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រីអៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំស្តីពីការពិនិត្យលទ្ធផលនៃការអនុវត្តការងារ ក្នុងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែឧសភា ឆ្នាំ២០១៦។

អង្គប្រជុំពិគ្រោះយោបល់ របស់តំណាង និងជនបង្គោលប្រជាជនងាយរងគ្រោះដោយសារជំងឺ (KAP) តំណាងខាងជំងឺទាំងបី គឺជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ ក៏ដូចជាតំណាងខាងអង្គការភក្តីភាព (FBO)។

នៅព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារ Himawari **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល (CCC) បានអញ្ជើញជាអធិបតីក្នុងពិធីបើកអង្គប្រជុំពិគ្រោះយោបល់ របស់តំណាង និងជនបង្គោលប្រជាជនងាយរងគ្រោះដោយសារជំងឺ (KAP) តំណាងខាងជំងឺទាំងបី គឺជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ (People Living with Diseases) ក៏ដូចជាតំណាងខាងអង្គការភក្តីភាព (FBO)។ ហើយក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណចំពោះបណ្តាអង្គការ និងស្ថាប័ន ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការផ្សេងៗរបស់មូលនិធិសកល ត្រូវបានទទួលស្គាល់ជាវិជ្ជមានពីគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល ក៏ដូចជាពីមូលនិធិសកលផងដែរ។

## ២.២. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

១. នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ឯកឧត្តមអគ្គលេខាធិការ បានចុះពិនិត្យ និងស្វែងយល់ពីស្ថានភាពអេដស៍នៅខេត្តកំពត ។

២. នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ឯកឧត្តមអគ្គលេខាធិការ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

## ២.៣. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ (PMER)

នៅក្នុងខែឧសភា ឆ្នាំ២០១៦នេះ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ (PMER) បានអនុវត្ត និងសម្រេចបានការងារមួយចំនួនដូចខាងក្រោម៖

**សកម្មភាពបានអនុវត្ត និងសកម្មភាពសម្រេចបាន ៖**

១. បន្តរៀបចំបញ្ជីឈ្មោះសៀវភៅ និងប្រមូលផ្ទាំងរូប ដែលមានទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ ហើយក៏បន្តទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីយកឯកសារមួយចំនួនដែលអាចដាក់ក្នុងបណ្ណាល័យ របស់អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។

២. នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ប្រធាន និងអនុប្រធាននាយកដ្ឋាន បានចូលរួមកិច្ចប្រជុំស្តីពីកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នៅក្រសួងផែនការ។

៣. បានរៀបចំលិខិតសម្រាប់ផ្ញើជូនបណ្តាស្ថាប័នពាក់ព័ន្ធ ដែលជាសមាសភាពក្នុងការបង្កើតក្រុមការងារជាតិសម្រាប់អង្កេតការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៤ -២០១៥ ដើម្បីជូនជាដំណឹង ដោយយោងតាមការសម្រេចលើលិខិតស្នើសុំបង្កើតក្រុមការងារជាតិ សម្រាប់អង្កេតការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៤-២០១៥ លេខ ១៦៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។

៤. បានធ្វើការពិនិត្យវិញចំពោះលិខិតស្នើសុំបំពេញលើទម្រង់ប្រមូលទិន្នន័យទាក់ទងនឹងការអង្កេតជាតិស្តីពី ការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៤ និង២០១៥ ដើម្បីផ្ញើជូនក្រសួង និងស្ថាប័នពាក់ព័ន្ធសម្រាប់ការបញ្ចូលទិន្នន័យក្នុងតារាងរបាយការណ៍ ការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍។

៥. បានបញ្ចប់ការប្រមូលបញ្ចូលទិន្នន័យរបាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ បានទទួលពីខេត្តចំនួន១៣ ។

៦. បានបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែឧសភា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីចងក្រងជារបាយការណ៍រួមប្រចាំខែ។

៧. បានធ្វើរបាយការណ៍សកម្មភាពអនុវត្តប្រចាំសប្តាហ៍ទី១ដល់ទី៤ ខែឧសភា ឆ្នាំ២១០៦ របស់នាយកដ្ឋាន PMER។

៨. នាយកដ្ឋានបានធ្វើសំណើជូនទៅថ្នាក់ដឹកនាំក្នុងការចុះអភិបាលកិច្ច និងពង្រឹងប្រព័ន្ធតាមដាន វាយតម្លៃ និងប្រមូលទិន្នន័យប្រចាំត្រីមាស នៅខេត្តកំពង់ឆ្នាំង និងបានធ្វើលិខិតជូនដំណឹងទៅថ្នាក់ខេត្ត ដើម្បីស្នើសុំឲ្យជួយ

សម្របសម្រួលដល់ក្រុមការងារបច្ចេកទេសបានចុះប្រមូលទិន្នន័យទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងការបំពេញលើរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ ។

១០. បានទំនាក់ទំនងជាមួយមន្ត្រីលទ្ធកម្មរបស់ PR-NCHADS ស្តីអំពីការរៀបចំលិខិតទទួល MCPI-SoP ពីទីប្រឹក្សាបច្ចេកទេស ដើម្បីជូនទៅ PR-NCHADS ។

១១. បានព្រាងលិខិតស្តីពីការទទួល MCPI-SoP ពីទីប្រឹក្សាបច្ចេកទេស ដើម្បីជូនទៅ PR-NCHADS។

## ២.៤. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៅក្នុង ខែឧសភា ឆ្នាំ២០១៦នេះ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានអនុវត្ត និងសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោមៈ

**សកម្មភាពបានអនុវត្តៈ**

១. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានជួប ប្រជុំជាមួយក្រសួងផែនការ ដើម្បីពិនិត្យតួលេខអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលនឹងទទួលបានប័ណ្ណក្រីក្រនៅក្នុង៨ខេត្ត (បាត់ដំបង ប៉ៃលិន ព្រះវិហារ ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ រតនៈគិរី និងកណ្តាល ) ជាលទ្ធផល ក្រសួងផែនការបានឯកភាពលើតួលេខដែលបានស្នើសុំ ប៉ុន្តែស្នើសុំកែសម្រួលបញ្ជីឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដោយដាក់អាសយដ្ឋានត្រឹមតែ ភូមិ ឃុំ ស្រុក ខេត្ត បានហើយ។

២. បន្តការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦។

៣. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានជួបប្រជុំជាមួយអង្គការ Women CRS CPR និង CPN+ ស្តីពីនីតិវិធីបន្តទាក់ទងនឹងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលទទួលបានប័ណ្ណ សមធម៌ សម្រាប់អនុវត្តក្នុងខែមិថុនា។

៤. រៀបចំពង្រាងបទបង្ហាញ សម្រាប់វគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ខេត្ត ស្រុក សង្កាត់-ឃុំសម្រាប់ការចុះជ្រើសរើសអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលនឹងទទួលបានប័ណ្ណក្រីក្រ នាខែមិថុនា ឆ្នាំ២០១៦។

៥. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានជួប ប្រជុំជាមួយក្រសួងផែនការដើម្បីកែសម្រួលបញ្ជីឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដោយដាក់អាសយដ្ឋានត្រឹមតែភូមិ ឃុំ ស្រុក ខេត្ត សម្រាប់៨ខេត្ត ( បាត់ដំបង ប៉ៃលិន ព្រះវិហារ ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ រតនៈគិរី និងកណ្តាល)។

៦. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៦ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៦ ក្រោមរបៀប វារៈដូចខាងក្រោម៖

- របាយការណ៍សង្ខេបប្រចាំខែមេសា និងខែឧសភា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ការបង្ហាញពីស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅភូមិរកា ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។
- ការបង្ហាញពីស្ថានភាពស្តីពីការចុះប្រមូលទិន្នន័យទាក់ទងនឹងការផ្តល់ប័ណ្ណក្រីក្រ ក្នុងចំណោមគ្រួសារអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។
- និងបញ្ហាផ្សេងៗ

៧. ចុះស្រង់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលនឹងទទួលបានប័ណ្ណសមធម៌នៅខេត្តតាកែវ។

៨. បានចូលរួមរៀបចំផែនការឆ្លើយតបមេរោគអេដស៍រយៈពេល១ឆ្នាំ គឺឆ្នាំ២០១៧ នៅក្នុងឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ដោយសម្របសម្រួលឲ្យមាន៖

- បញ្ហាបុគ្គលិកដែលត្រូវធ្វើការងារសុខភាពនៅសហគមន៍
- បញ្ហាប្រជុំសម្របសម្រួលជាមួយអ្នកផ្ទុកមេរោគអេដស៍
- ជីវភាពប្រចាំថ្ងៃ
- បញ្ហាស្ពានអណ្តូងទឹក បង្គន់អនាម័យ ផ្លូវក្រាលកៅស៊ូ។ល។

៩. បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តកំពត និងខេត្តក្រចេះ។ ជា លទ្ធផល គណៈកម្មាធិការអេដស៍ខេត្ត នៅតែបានសហការគ្នាអនុវត្តគោលនយោបាយ៧ចំណុច របស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ បានយ៉ាងល្អ ទោះបីជួបបញ្ហាកង្វះថវិកាយ៉ាងណាក៏ដោយ។ ប៉ុន្តែ

យើងរកឃើញថានៅតែមានអ្នកផ្ទុកមេរោគអេដស៍ថ្មីនៅឡើយ នេះសបញ្ជាក់ថាមេរោគអេដស៍ នៅតែបន្តចម្លងដោយស្ងៀមស្ងាត់។

១០. បានចុះពិនិត្យស្ថានភាពមេរោគអេដស៍ និងការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តព្រះសីហនុដោយមានការចូលរួមពីលោកជំទាវអភិបាលរងខេត្ត លោកស្រីប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត មន្ត្រីកម្មវិធីអេដស៍ អង្គការខេមរា AHF បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍។ ជាលទ្ធផល គណៈកម្មាធិការ ប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត នៅតែបានសហការគ្នាអនុវត្តសកម្មភាពបានយ៉ាងល្អ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ទោះបីជួបបញ្ហាកង្វះថវិកាយ៉ាងណាក៏ដោយ។

១១. Follow up ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦។

១២. ប្រជុំពិគ្រោះយោបល់លើឯកសារបណ្តុះបណ្តាល សម្រាប់ជ្រើសរើសគ្រូសារក្រីក្រ ដើម្បីទទួលបានប័ណ្ណសមធម៌ជាមួយក្រសួងផែនការ។

## ២.៥. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

នៅក្នុងខែឧសភា ឆ្នាំ២០១៦នេះ នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ បានអនុវត្ត និងសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

**សកម្មភាពបានអនុវត្ត និងសកម្មភាពសម្រេចបាន ៖**

១. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំភាក្សា និងកែសម្រួលលើឯកសារនិយាម ប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូរវាងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍និងសហគមន៍ នៅសាលប្រជុំ អ.ជ.ប.ជ.អ។

២. នៅថ្ងៃទី០៣ ដល់ទី៥ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមលើកផែនការថវិកាជាតិសម្រាប់ឆ្នាំ២០១៧ របស់នាយកដ្ឋាន និងរៀបចំឯកសារសម្រាប់កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រលាញ់បុរស និងស្រីស្រស់។

៣. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ បានរៀបចំកិច្ចប្រជុំប្រចាំនាយកដ្ឋាន ដើម្បីកែសម្រួលតួនាទី និងភារៈកិច្ចមន្ត្រីក្នុងនាយកដ្ឋាន និងពង្រឹងវត្តមានប្រចាំថ្ងៃ។

៤. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យពិភាក្សា និងកែសម្រួលលើឯកសារនិយាមប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូ រវាង

ក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ ជំងឺអេដស៍ និងសហគមន៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ បានរៀបចំកិច្ចប្រជុំប្រចាំខែក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីពិនិត្យពិភាក្សា និងកែសម្រួលបញ្ចប់លើរបាយការណ៍ប្រចាំឆ្នាំ និងសេចក្តីសម្រេចក្រុមការងារបច្ចេកទេស ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៦. សម្របសម្រួលរៀបចំថវិកាមូលនិធិសកលសម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំសិក្ខាសាលាស្តីពីលក្ខខណ្ឌការងារល្អប្រសើរ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថានក្រុមហ៊ុនសេវាកម្សាន្តដល់បុគ្គលិកអង្គការសហាជីព។

៧. នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំពិភាក្សាក្នុងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយប្រចាំ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៨. នៅថ្ងៃទី១៨ ដល់ទី១៩ ខែឧសភា ឆ្នាំ២០១៦ ចាត់មន្ត្រីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យកុមារ OVC នៅក្នុងសហគមន៍ និងពិភាក្សាស្តីពីផែនការរៀបចំអាស្រ័យ និងប្រភេទសេវាដែលផ្តល់ដោយអង្គការ នៅឃុំ សង្កាត់ ក្រុង ខ័ណ្ឌ នៅក្នុងខេត្តបាត់ដំបង ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យកុមារ OVC តាមប្រភេទនិយមន័យ មុននឹងប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅក្នុងខេត្ត ដើម្បីឈានទៅដោះស្រាយ និងគ្រប់គ្រងករណីឲ្យទទួលបានលទ្ធផលល្អតាមផែនការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៣- ២០១៨។

៩. បានបញ្ចប់ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងសេចក្តីសម្រេចក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

១០. សម្របសម្រួលរៀបចំថវិកាមូលនិធិសកលសម្រាប់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំសិក្ខាសាលាស្តីពីលក្ខខណ្ឌការងារល្អប្រសើរ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថានក្រុមហ៊ុនសេវាកម្សាន្តដល់បុគ្គលិកអង្គការសហាជីព។

១១. បានចូលរួមកិច្ចប្រជុំ ដើម្បីបន្តពិនិត្យពិភាក្សា និងកែសម្រួលលើឯកសារ និយាមប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូ រវាងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសហគមន៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ២.៦. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

នៅក្នុងខែឧសភា ឆ្នាំ២០១៦នេះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដែលក្នុងនោះមាន៥ការិយាល័យ និងបានបំពេញសកម្មភាពការងារដូចខាងក្រោម៖

**ស្ថានភាពទូទៅ៖**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជាសេនាធិការជូនថ្នាក់ដឹកនាំលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ហើយជាអ្នកសម្របសម្រួល និងគាំទ្រ ដល់បណ្តានាយកដ្ឋានបច្ចេកទេស ដើម្បីអនុវត្តផែនការសកម្មភាពឱ្យមានការរីកចម្រើន។ នាយកដ្ឋាន ដែលមាន៥ការិយាល័យនេះ បានបំពេញសកម្មភាពការងារដូចខាងក្រោម៖

**ការងារអនុវត្តសម្រេចបាន៖**

១. បានទទួលលិខិតចូលចំនួន ១៩។
២. បានបញ្ជូនលិខិតចេញទៅបណ្តារាជធានី-ខេត្តចំនួន១៤។
៣. បានបញ្ជូនលិខិតចេញទៅក្រសួងចំនួន១៣។
៤. បានរៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ-មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៥។
៥. បានរៀបចំលិខិតចាត់តាំងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។
៦. បានធ្វើលិខិតចុះពិនិត្យមើលស្ថានភាពដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍។
៧. បានធ្វើលិខិតជម្រាបទៅ PAC ខេត្តកំពង់ស្ពឺ ស្តីពីឯកឧត្តមអគ្គលេខាធិការចុះពិនិត្យមើលស្ថានភាពដល់អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។
៨. បានធ្វើលិខិតអញ្ជើញប្រជុំ PAB ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦។
៩. បានធ្វើលិខិតស្នើសុំថវិកាសម្រាប់ចំណាយការប្រើប្រាស់ ក្នុងអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។
១០. បន្តរៀបចំសលាកប័ត្រឃ្លាំងក្នុងអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។

១១. ទំនាក់ទំនងក្រសួងមុខងារសាធារណៈ អំពីការពង្រឹងពេលវេលាការងារថ្នាក់ដឹកនាំ ស្តីពីពេលវេលាធ្វើការរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។
១២. រៀបចំគំរូបញ្ជីវត្តមានថ្មីតាមអនុក្រឹត្យ ៥៦ ស្តីពីការពង្រឹងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។
១៣. រៀបចំការបែងចែកតួនាទី ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។
១៤. រៀបចំឯកសារដំឡើងកាំប្រាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍។
១៥. ប្រមូលរបាយការណ៍ប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា។
១៦. រៀបចំឯកសារដាក់លោកវេជ្ជ. រស់ សីលវ៉ាត់ ស្ថិតក្នុងភាពទំនេរពីការងារដោយរក្សាទុកនូវមុខដំណែង និងបៀវត្សដដែល។
១៧. ស្នើសុំឥណទានថវិកាជាតិជំពូក ៦៤ ប្រាក់បៀវត្សមន្ត្រីជាប់កិច្ចសន្យាប្រចាំខែឧសភា ឆ្នាំ២០១៦ រួចរាល់។
១៨. រៀបចំសរុបបញ្ចូលទឹកប្រាក់បេសកកម្មទាំងអស់ (មូលប្បទានបត្រ) ទៅធនាគារអេស៊ីលីដា។
១៩. ពិនិត្យតាមដានឥណទានជាប្រចាំ។
២០. ទំនាក់ទំនងជាមួយក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ ក្នុងការបិទបញ្ជីឆ្នាំចាស់២០១៥ បន្តការងារឆ្នាំ២០១៦។
២១. បញ្ចូលអាណត្តិដែលបានរៀបចំទូទាត់រួច ទៅអង្គភាពទាំងបីខាងលើ។
២២. លើកគោលការណ៍ប្រជុំពេញអង្គលើកទី១។

# ៣. ផែនការសកម្មភាព និងទិសដៅសម្រាប់ខែកក្កដា ឆ្នាំ២០១៦

## ៣.១. នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

**ការងារសម្រាប់ខែបន្ទាប់៖**

១. បន្តពិនិត្យមើលការងារ NASA និង វគ្គសិក្សាខ្លីៗពី NASA ។
២. បន្តពិនិត្យមើលការងារ NSP IV ។
៣. បន្តពិនិត្យមើលរបាយការណ៍ប្រចាំឆ្នាំ២០១៥ ពីព្រោះមិនទាន់បានចងក្រងរួចរាល់។
៤. ធ្វើកំណត់ហេតុកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ និងបន្តចងក្រងរបាយការណ៍ខែមិថុនា ឆ្នាំ២០១៦របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. បន្តធ្វើរបាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦។

៦. បន្តទំនាក់ទំនងជាមួយ PR/NCHADS ទាក់ទងនឹងការងារអនុវត្តគម្រោង។

## ៣.២. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

### ការងារសម្រាប់ខែបន្ទាប់៖

១. ប្រជុំគណៈកម្មាធិការថវិកាស្តីពីការពិនិត្យលើកគម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦។

២. រៀបចំចាត់តាំងមន្ត្រីចុះបេសកកម្មខេត្តប៉ៃលិន នៅថ្ងៃទី២៤ ដល់ ទី២៦ ខែមេសា ឆ្នាំ២០១៦។

៣. Follow Up ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ដែលជាប់ជាគ្រួសារក្រីក្រ ដើម្បីទទួលបានប័ណ្ណសមធម៌ដែលធ្វើពីអង្គការបណ្ដាញអ្នកផ្ទុក។

៤. រៀបចំរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ។

## ៣.៣. នាយកដ្ឋាន បច្ចេក ថែទាំ និងគាំទ្រ

### ការងារសម្រាប់ខែបន្ទាប់៖

១. បន្តជួយដល់ក្រសួងពាក់ព័ន្ធ (ជាជំនួយបច្ចេកទេស និងចូលរួមសម្របសម្រួល) ក្នុងការរៀបចំកម្មវិធីស្តីពីកុមារកំព្រា និងកុមារដែលងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។

២. ចុះអភិបាលកិច្ច លើការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅតាមបណ្ដាខេត្ត។

៣. ចូលរួមកិច្ចប្រជុំនានា ដើម្បីពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការឆ្លើយតបនឹងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

៤. បន្តចូលរួមអនុវត្តផែនការមូលនិធិសកល និងផែនការថវិកាជាតិ។

៥. ចូលរួមប្រជុំបច្ចេកទេសជាមួយថ្នាក់ដឹកនាំ រៀងរាល់សប្តាហ៍ និងរៀងរាល់ខែ។

៦. តាមដាន និងពិនិត្យរាល់ការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និង ជំងឺអេដស៍ របស់រាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធ។

៧. ចូលរួមរៀបចំកិច្ចប្រជុំលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ នឹងរៀបចំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រចាំខែ និងត្រីមាស។

៨. បន្តតាមដានលើរបាយការណ៍វឌ្ឍនភាពរបស់ក្រុមប្រឈមមុខខ្ពស់ និងអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍។

## ៣.៤. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**ភារងារសម្រាប់ខែបន្ទាប់៖**

១. រៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ-មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

២. ធ្វើលិខិតស្នើសុំថវិកាសម្រាប់ចំណាយការប្រើប្រាស់ក្នុងអាជ្ញាធរ។

៣. បន្តរៀបចំសលាកប័ត្រឃ្លាំង។

៤. បន្តរៀបចំបញ្ជីវត្តមានថ្មីតាមអនុក្រឹត្យ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

៥. បន្តរៀបចំតារាងបញ្ចូលទឹកប្រាក់បេសកកម្មទាំងអស់ (មូលប្បទានប័ត្រ) ទៅធនាគារអេស៊ីលីដា។

៦. បន្តរៀបចំគោលការណ៍សម្រាប់ប្រជុំពេញអង្គនៅ NewYork ។

ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៦

មន្ត្រីទទួលបន្ទុក

**លោកវេជ្ជ. កែវ ចំណាន**

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

**លោកវេជ្ជ. ទេព ណារុធ**

បានឃើញ និងឯកភាព

អគ្គលេខាធិការ

**ឯកឧត្តមវេជ្ជ. តែង គន្ធី**